# តើយើងអាចរំពឹងអ្វីពីព្រះអម្ចាស់ ក្នុងពេលឥឡូវនេះ? (តែងសេចក្តីទី៦/៧)

ដោយ Tim Geoffrion

## សេចក្តីពិត ទី៦៖ ចូររំពឹងចង់បានសេចក្តីសុខសាន្តថែមទៀត ខណៈពេលដែលអ្នកផ្ទេរសេចក្តីថប់បារម្ភរបស់អ្នក ដាក់ក្នុងព្រះសហ្គដ៏មានព្រះចេស្តារបស់ព្រះ។



នៅថ្ងៃខ្លះ ភាពតានតឹងហាក់ដូចជាកាន់តែយ៉ាប់យ៉ឺនទៅៗ មិនប្រសើរទេ។ ខ្ញុំកំពុងបន្តមានបញ្ហាក្នុងការគេងមិនលក់ស្រួលនៅពេលយប់។ កាលពីថ្ងៃព្រហស្បតិ៍កន្លងទៅនេះ នៅពេលដែលខ្ញុំកំពុងមានការរសាប់រសល់ក្នុងពេលទទួលទានដំណេក ខ្ញុំស្រាប់តែនឹកឃើញជញ្ជាំងទឹកដ៏ធំមួយ មានកំពស់ ជាង ១៥ ម៉ែត្រ នៅខាងឆ្វេងដៃខ្ញុំ។ នៅផ្នែកម្ខាងទៀត ខ្ញុំអាចមើលឃើញភ្នំទឹកមួយ ដែលមើលទៅដូចជាអាចផ្ទុះឡើងនៅពេលណាមួយ។ ខ្ញុំមិនដឹងថាតើខ្ញុំគិតថានឹងមានអ្វីកើតឡើងទៀត - ធ្វើឲ្យខ្ញុំរសាត់ចេញទៅ? ធ្វើឲ្យខ្ញុំលង់ទឹក? ធ្វើបាបខ្ញុំតាមរបៀបផ្សេងទៀត? ខ្ញុំមិនដឹងថាខ្ញុំភ្ញាក់ ឬដេកលក់ទេតែវាគួរអោយខ្លាចណាស់។ ទំនប់ហៀបនឹងបាក់ ហើយខ្ញុំមិនដឹងថាខ្ញុំអាចធ្វើអ្វីដើម្បីការពារខ្លួនខ្ញុំទេ។

នៅពេលដែលខ្ញុំមានអារម្មណ៍អន្ទះសាដូចនេះ សន្តិភាពនិងអំណររបស់ខ្ញុំ នឹងរលាយបាត់ទៅ។ ខ្ញុំធ្លាប់ខាំក្រចកដៃពេលខ្ញុំនៅក្មេង។ ឥឡូវ ខ្ញុំភាគច្រើនតានតឹងឬទាល់ច្រក។ ខ្ញុំមានបញ្ហាក្នុងការផ្តោតអារម្មណ៍ឬភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃ។ ប្រសិនបើវាមិនល្អគ្រប់គ្រាន់ (ដូចជាកាលពីថ្ងៃមុន) ខ្ញុំស្ទើរតែមិនអាចសន្ទនា ឬមើលទៅមនុស្សផ្សេងទៀតចំភ្នែកផ្ទាល់។ យើងបានស្នាក់នៅផ្ទះអស់រយៈពេលជិត ៨ សប្តាហ៍ហើយ។ ខណៈពេលដែលខ្ញុំធ្លាប់រស់នៅតាមរបៀបនេះ ហើយថែមទាំងរីករាយនឹងពេលវេលាបន្ថែមនៅផ្ទះ និងជាមួយគ្រួសារ ភាពតានតឹងតែងតែមាន។ ហើយវាចេះតែកើនឡើង។

តើយើងអាចរំពឹងអ្វីពីព្រះ នៅពេលមានរឿងគួរឱ្យភ័យខ្លាច ឬមិនដឹងអំពីអនាគត? តើព្រះអាចធ្វើអ្វីបានសម្រាប់យើង នៅពេលដែលការថប់បារម្ភរបស់យើងធំធេង ដែលយើងមិនអាចដំណើរការបានធម្មតា ហើយយើងមិនអាចធ្វើជាមនុស្សដែលយើងចង់ធ្វើបាន?

**សេចក្តីពិតខាងវិញ្ញាណ ៦៖ រំពឹងថានឹងមានសន្តិភាពកាន់តែច្រើននៅពេលដែលអ្នកដាក់កង្វល់របស់អ្នកនៅក្នុងព្រះហស្តដែលមានសមត្ថភាពរបស់ព្រះ។** (**ភីលីព ៤: ៦-៧**)

សាវកប៉ូលបានដឹងយ៉ាងច្បាស់ថា គ្រីស្ទបរិស័ទជាច្រើន ទោះបីជាពួកគេមានជំនឿរឹងមាំក៏ដោយ ក៏នៅតែមានការថប់បារម្ភដែរ។ នេះជាធាតុពិតនៃមនុស្ស។ ប៉ុន្តែ នេះមិនមែនមានន័យថា យើងត្រូវតែក្លាយជាអ្នកទោសចំពោះការព្រួយបារម្ភរបស់យើងនោះទេ។ ដូច្នេះ គាត់បានផ្តល់នូវរូបមន្តដ៏សាមញ្ញនេះដោយសន្យាថា ប្រសិនបើយើងធ្វើតាម នោះសន្តិភាពរបស់ព្រះនឹងការពារចិត្ត និងគំនិតរបស់យើង។ តើរូបមន្តរបស់គាត់គឺជាអ្វី?

> កុំឲ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះ ឲ្យជ្រាបពីសេចក្ដីសំណូមរបស់អ្នករាល់គ្នាក្នុងគ្រប់ការទាំងអស់ ដោយសេចក្ដីអធិស្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង។ យ៉ាងនោះ សេចក្ដីសុខសាន្តរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិត និងជួយការពារចិត្ត ហើយនិងគំនិតរបស់អ្នករាល់គ្នា ក្នុងព្រះគ្រីស្ទយេស៊ូវ។
>
> *ភីលីព ៤:៦-៧*

ប្រសិនបើយើងបែងចែកការណែនាំរបស់ប៉ូលទៅជាជំហានៗ យើងអាចមើលឃើញយ៉ាងងាយស្រួល នូវអ្វីដែលយើងត្រូវធ្វើ នៅពេលណាដែលយើងមានកង្វល់។

1. **ទទួលស្គាល់ថា អ្នកប្រហែលជាមានការថប់បារម្ភច្រើនជាងអ្វីដែលអ្នកបានដឹង។** ជាធម្មតា រោគសញ្ញារួមមានអារម្មណ៍ភ័យ ឬតានតឹងទៅលើអ្វីមួយ ដែលអ្នកមានការព្រួយបារម្ភ ឬការភ័យខ្លាចចំពោះរឿងដែលមិនសមហេតុផល ឬក៏មានអារម្មណ៍នឿយហត់ ឬខ្សោយ ឬមួយក៏មានបញ្ហាក្នុងការគេងជាដើម។ ប្រសិនបើអ្នកមានអារម្មណ៍ធុញថប់ សូមកុំបដិសេធវា ឬព្យាយាមធ្វើពុតជាអ្វីមួយដែលមិនមែនជាអ្នក។ ការទទួលស្គាល់ការថប់បារម្ភរបស់អ្នក គឺជាជំហានដំបូងឆ្ពោះទៅរកការរួចផុតពីវា។
2. **ឈោងទៅរកព្រះ។** នៅពេលអ្នកមានទុក្ខព្រួយ ព្រះអាទិករនិងជាព្រះអង្គសង្គ្រោះរបស់អ្នក ដែលប្រកបដោយសេចក្តីស្រឡាញ់ ទ្រង់នៅទីនោះជាមួយអ្នក។ គោលដៅសំខាន់នៃការអធិស្ឋាន នៅពេលនេះ គឺដើម្បីចេញពីភាពអាត្មានិយម ហើយភ្ជាប់ទំនាក់ទំនងជាមួយព្រះ ដើម្បីឱ្យទ្រង់អាចលើកអ្នក ចេញពីរណ្តៅខ្មៅងងឹត នៃការថប់បារម្ភរបស់អ្នក។ សូមបើកបង្ហូរដួងចិត្តរបស់អ្នក ទៅកាន់ព្រះអង្គ។ ស្វែងរកការកម្សាន្តចិត្តដែលបានមកពីការចូលទៅជិតទ្រង់ ហើយសម្រាកនៅក្នុងវត្តមានរបស់ទ្រង់ ដូចដែលខ្ញុំបានពិភាក្សានៅក្នុងអត្ថបទមុនរបស់ខ្ញុំ។
3. **ទូលសុំព្រះសម្រាប់អ្វីគ្រប់យ៉ាង ដែលអ្នកចង់បាន និងត្រូវការ។** ធ្វើជាបញ្ជី ហើយប្រាប់ព្រះ នូវអ្វីដែលអ្នកព្រួយបារម្ភ និងអ្វីគ្រប់យ៉ាងដែលអ្នកចង់ឱ្យទ្រង់ជួយ។ នេះមិនដូចជាការបន្តោងជើងទន្សាយ ឬត្រដុសរូបសំណាកសាសនា ឬឆ្លាក់អ្វីមួយដោយសង្ឃឹមថា នឹងបញ្ចេញថាមពលវេទមន្តឬបង្ខំព្រះឱ្យធ្វើតាមចិត្តរបស់អ្នកឡើយ។ វាជាការពិត ប៉ូលធានាដល់ពួកភីលីពថា៖ «**ព្រះនៃខ្ញុំ ទ្រង់នឹងបំពេញគ្រប់ទាំងអស់ ដែលអ្នករាល់គ្នាត្រូវការ**

**តាមភោគសម្បត្តិនៃទ្រង់ដ៏ឧត្តម ក្នុងព្រះគ្រីស្ទយេស៊ូវ»** (ភីលីព ៤:១៩) ប៉ុន្តែគាត់មិនបានសន្យាថា គ្រាន់តែអធិស្ឋាន នោះអ្នកនឹងទទួលបានអ្វីគ្រប់យ៉ាងដែលអ្នកសុំនោះឡើយ។ មិនមែនទេ អ្វីដែលគាត់សន្យាចំពោះអស់អ្នកដែលទូលប្រាប់អស់ទាំងសំណូមពររបស់ពួកគេដល់ព្រះ នោះគឺជាសេចក្តីសុខសាន្ត។

4. **ទាំងពោលពាក្យអរព្រះគុណផង ខណៈពេលដែលអ្នកកំពុងស្នើសុំជំនួយនោះ។** កុំយកចិត្តទុកដាក់ចំពោះកង្វល់ និងសេចក្តីប្រាថ្នារបស់អ្នក ក្នុងសេចក្តីអធិស្ឋានរបស់អ្នក។ ជ្រើសរើសផ្តោតលើអ្វី ដែលអ្នកដឹងគុណ ក៏ដូចជាអ្វីដែលខ្វះនៅក្នុងជីវិតរបស់អ្នក។ " រាប់ចំនួនព្រះពររបស់អ្នក ហើយរៀបរាប់ឈ្មោះព្រះពរនោះម្តងមួយៗ"។ នៅពេលទទួលទានអាហារក្នុងគ្រួសារយើង មុនពេលយើងអធិស្ឋាន មនុស្សគ្រាប់គ្នាចែករំលែក នូវអ្វីដែលពួកគេដឹងគុណពេញមួយថ្ងៃ ដូចជាអ្វីមួយដែលពួកគេបានឃើញព្រះធ្វើការ ក្នុងជីវិតរបស់ពួកគេ ឬបទពិសោធន៍មួយដែលបាននាំពួកគេចូលកាន់តែជិតព្រះ។ វាពិតជាធ្វើឲ្យមានអារម្មណ៍ "វិសេសវិសាល" នៅជុំវិញតុ។ តែងតែមានហេតុផលជាច្រើន ដែលធ្វើឱ្យយើងមានអារម្មណ៍ថប់បារម្ភ ខឹង ឬក្រៀមក្រំ ដូច្នេះការចែករំលែកពាក្យអរព្រះគុណ ធ្វើអោយជីវិតស្រស់ថ្លាខ្លះ ចូលក្នុងចិត្តគំនិត និងបេះដូងរបស់មនុស្សគ្រប់គ្នា។ មិត្តល្អម្នាក់របស់ខ្ញុំ បានប្រាប់ខ្ញុំកាលពីពេលថ្មីៗនេះថា នាងកំពុងព្យាយាម "ជ្រើសរើសសេចក្តីអំណរ" ដោយដឹងខ្លួនជារៀងរាល់ថ្ងៃ ទោះបីជាមានអ្វីផ្សេងទៀត ដែលធ្វើឱ្យនាងចុះខ្សោយក៏ដោយ។ អាកប្បកិរិយាដែលយើងជ្រើសរើសធ្វើឱ្យមានភាពខុសគ្នា។

លោកប៉ូលដឹងយ៉ាងច្បាស់ថា ប្រសិនបើយើងទុកឱ្យខ្លួនយើងរស់នៅលើការភ័យខ្លាច និងបញ្ហារបស់យើង នោះយើងនឹងកាន់តែមានការថប់បារម្ភ មិនតិចទេ។ ផ្ទុយទៅវិញ ប្រសិនបើយើងមានស្មារតី និងការជំនួសការថប់បារម្ភរបស់យើងដោយញ្ញាចិត្តនិងជាលក្ខណៈប្រព័ន្ធ នោះលទ្ធផលនឹងមានសេចក្តីសុខសាន្តកាន់តែខ្លាំង។ ដូចដែលខ្ញុំបាននិយាយរួចហើយ ក្នុងការអធិស្ឋានតាមវិធីនេះ យើងមិនគួរបដិសេធការថប់បារម្ភរបស់យើងទេ។ ផ្ទុយទៅវិញ យើងត្រូវទទួលស្គាល់អំណាច ដែលវាមានលើយើង ហើយទូលទៅកាន់ព្រះដោយផ្ទាល់ អំពីការភ័យខ្លាច និងកង្វល់របស់យើង។ ដូចគ្នានេះដែរ ការអធិស្ឋានដោយការអរព្រះគុណ មិនមែនគ្រាន់តែជាការគិតវិជ្ជមាន ឬកាត់បន្ថយការព្រួយបារម្ភរបស់យើងទេ (ថ្វីដ្បិតតែការគិតវិជ្ជមាន សំខាន់មែនក៏ដោយ) ។ ផ្ទុយទៅវិញ ការអធិស្ឋានប្រភេទនេះ ភ្ជាប់ស្មារតីរបស់យើងជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ ដូច្នេះយើងអាចទទួលបានជំនួយខាងវិញ្ញាណដែលព្រះចង់ប្រទានដល់យើងនៅពេលមានទុក្ខលំបាក។ អ្វីដែលនាំមកនូវសេចក្តីសុខសាន្តដល់យើង គឺព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដែលជួយយើងតាមរយៈការអធិស្ឋាន ហើយជួយអោយយើងរួចផុតពីបន្ទុក ដែលយើងបានព្យាយាមអនុវត្តតែម្នាក់ឯង ឬដោយកម្លាំងផ្ទាល់របស់យើង។



*អធិស្ឋានជាមួយគ្រួសារភូមា (យ៉ែងហ្គូន ប្រទេសមីយ៉ាន់ម៉ា)*

### *ពាក្យប្រៀបប្រដូចដ៏មានទំនងមួយ*

មានពេលមួយ ពេលកូនប្រុសច្បងរបស់ខ្ញុំ មានអាយុប្រហែលជា ប្រាំមួយ ឆ្នាំប៉ុណ្ណោះ គាត់ឈឺធ្ងន់ណាស់។ រាល់ពេលដែលយើងព្យាយាមឱ្យទឹកគាត់ផឹកគាត់នឹងក្អួត។ យើងបានមើលគាត់ចុះខ្សោយនិងខ្សោយទៅៗ ខណៈពេលវេលាចេះតែកន្លងទៅជាច្រើនថ្ងៃ។ វេជ្ជបណ្ឌិតបានណែនាំខ្ញុំ ឱ្យនាំគាត់ចូលមន្ទីរពេទ្យ ប៉ុន្តែ ខ្ញុំគិតថា ខ្ញុំអាចថែទាំបីបាច់គាត់ឱ្យមានសុខភាពល្អឡើងវិញ។ ពេលមេឃងងឹត ខ្ញុំរៀបចំកន្លែងគេងលើឥដ្ឋក្បែរគាត់។ ខ្ញុំនៅតែគិតថា ប្រសិនបើគាត់អាចដេកលក់បាន គាត់នឹងជាឡើងវិញ។ ប៉ុន្តែ វាមិនមែនទេ។ ខ្ញុំសឹងតែទ្រាំលែងបាន ដោយសារការដែលត្រូវភ្ញាក់ ដែលបណ្តាលមកពីការក្អួក និងភាពមិនស្រួលខ្លួនរបស់គាត់ ម្តងហើយម្តងទៀត។

នៅពេលដែលកាន់តែច្បាស់ថា គាត់នឹងមិនអាចគេងលក់ ឬទប់ជាតិរាវបានទេ ខ្ញុំកាន់តែព្រួយបារម្ភខ្លាំងឡើងៗ។ ទីបំផុត ដោយការអស់សង្ឃឹម ខ្ញុំបានទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់គាត់ម្តងទៀត ដែលបានអង្វរខ្ញុំម្តងទៀត ឱ្យនាំគាត់ទៅបន្ទប់សង្គ្រោះបន្ទាន់។ លើកនេះខ្ញុំស្តាប់។ ពេលយើងមកដល់ម៉ោង ២ ឬ ៣ ព្រឹក ខ្ញុំបានដាក់ខ្លួនកូនប្រុសខ្ញុំ ដែលហៀបនឹងអស់ជីវិត ទៅក្នុងដៃរបស់គ្រូពេទ្យ។ វេជ្ជបណ្ឌិតបានក្រឡេកមើលគាត់ ហើយបន្ទាប់មក បានដាស់តឿនខ្ញុំយ៉ាងលឿនដោយនិយាយថា "អ្នកគួរតែនាំគាត់មកឆាប់ជាងនេះ" ។

ខ្ញុំពិតជាល្ងង់ណាស់! ខ្ញុំប្រថុយជីវិតកូនប្រុសខ្ញុំ។ ជំនួសឱ្យការទទួលបានជំនួយ ដែលគាត់ត្រូវការ ខ្ញុំបែរជាបានសម្រេចចិត្តបំពេញគំនិតខ្ញុំ ក្នុងពេលដំណាលគ្នាជាមួយនឹងក្តីសង្ឃឹមមិនពិត រួចមកក៏ច្របូកច្របល់ក្នុងការថប់បារម្ភរបស់ខ្ញុំ។ ខ្ញុំត្រូវជាប់គាំងនៅក្នុងរបៀបនៃការគិត និងការប្រព្រឹត្តរបស់ខ្ញុំ។ ទាំងគាត់និងខ្ញុំ ទាំងពីរបានបង់ថ្លៃដោយព្រោះការសម្រេចចិត្តនោះ។

ខ្ញុំបានគិតអំពីយប់នោះជាច្រើនដង ក្នុងរយៈពេល ២៨ ឆ្នាំកន្លងមកនេះ។ វាជាមេរៀនពិតមួយសម្រាប់ខ្ញុំ អំពីវិធីដោះស្រាយបញ្ហាសុខភាពធ្ងន់ធ្ងរ។ សំខាន់ជាងនេះទៅទៀត វាជាការរំឭកជាប់ជារហូត ដើម្បីកុំឲ្យខ្ញុំព្យាយាមយកបន្ទុក និងកង្វល់ទាំងអស់មកដាក់លើស្មាខ្ញុំខ្លួនឯង។ នៅពេលដែលខ្ញុំដាក់កូនប្រុសរបស់ខ្ញុំ នៅក្នុងការថែទាំរបស់វេជ្ជបណ្ឌិត ខ្ញុំមានអារម្មណ៍ធូរស្បើយណាស់។ ខ្ញុំមិនដឹងច្បាស់ថាតើកូនប្រុសរបស់ខ្ញុំអាចត្រូវបានសង្គ្រោះទេ ប៉ុន្តែ ខ្ញុំដឹងថាខ្ញុំបានទៅរកកន្លែងដែលអាចទទួលបានជំនួយ។ (អរគុណណាស់ ដែលគាត់បានជាសះស្បើយ ហើយពេលនេះគាត់មានអាយុ ៣៣ ឆ្នាំហើយ)។

ខាងវិញ្ញាណវិញ បទពិសោធន៍របស់ខ្ញុំបានក្លាយជាភាពស្រដៀងគ្នាមួយសម្រាប់របៀបធៀបការដោះស្រាយរាល់កង្វល់ និងការព្រួយបារម្ភខ្លាំងពេករបស់ខ្ញុំ។ សព្វថ្ងៃនេះ រាល់ពេលដែលខ្ញុំកត់សម្គាល់ឃើញថា ការថប់បារម្ភរបស់ខ្ញុំកើនឡើង នោះជាការអំពាវនាវអោយអធិស្ឋាន។ ដូចជាខ្ញុំបានក្រសោបកូនប្រុសរបស់ខ្ញុំ នៅក្នុងដៃរបស់ខ្ញុំនៅយប់ដ៏គួរឱ្យភ័យខ្លាចមួយ គឺជាពេលដែលគាត់ឈឺធ្ងន់នោះ ហើយបាននាំគាត់ទៅជួបគ្រូពេទ្យ ឥឡូវនេះ ខ្ញុំតែងតែប្រមូលគ្រប់អស់ទាំងការដែលខ្ញុំព្រួយបារម្ភ ហើយដាក់វាទៅក្នុងព្រះហស្តនៃព្រះវរបិតារបស់ ខ្ញុំ។ ម្តងហើយម្តងទៀត ខ្ញុំឆាប់មានអារម្មណ៍ធូរស្បើយ និងមានសេរីភាព ពីទុក្ខលំបាករបស់ខ្ញុំ។ សេចក្តីសុខសាន្ត ដែលខ្ញុំបានស្គាល់ គឺដូចប៉ូលបានរៀបរាប់មែន។ វា «លើសពីការយល់ដឹងទាំងអស់» ហើយការពារដួងចិត្ត និងគំនិតខ្ញុំពីអំណាចនៃការខ្វល់ខ្វាយ និងការថប់បារម្ភដ៏ហួសប្រមាណ។

*មេរៀនសម្រាប់ការអនុវត្តខាងវិញ្ញាណ*
តើអ្នកដោះស្រាយកង្វល់របស់អ្នកសព្វថ្ងៃនេះយ៉ាងដូចម្តេច?

ការណែនាំរបស់សាវកប៉ូលទៅកាន់ពួកជំនុំក្រុងភីលីព ក៏ជាពាក្យទូន្មានសម្រាប់អ្នកដែរ។

1. ទទួលស្គាល់ការថប់បារម្ភរបស់អ្នក។
2. សូមឈោងទៅរកទំនាក់ទំនងជាមួយព្រះ ទោះបីអ្នកបានត្រឹមតែនិយាយអ្វី ដែលសាមញ្ញក្តី ដូចជា "ព្រះវរបិតា ជួយខ្ញុំផង" " ព្រះយេស៊ូវ ទទួលបន្ទុកខ្ញុំផង" ឬ " ព្រះវិញ្ញាណបរិសុទ្ធអើយ ដោះលែងខ្ញុំ ឲ្យមានសេរីភាពផង"។
3. ប្រសិនបើអ្នកអាចអធិស្ឋានបានកាន់តែច្បាស់ សូមទូលប្រាប់រាល់កង្វល់ និងកង្វល់របស់អ្នកជាមួយព្រះ។ ទូលសូមទ្រង់សម្រាប់អ្វីគ្រប់យ៉ាង ដែលអ្នកចង់បាន និងត្រូវការ។ ផ្ទេរនូវរាល់បន្ទុកទាំងអស់របស់អ្នក ... ហើយដាក់នៅក្នុងព្រះហស្តរបស់ទ្រង់ចុះ។
4. ជំនួសការថប់បារម្ភរបស់អ្នក ដោយការអរព្រះគុណ នៅពេលអ្នកអធិស្ឋាន។ រាប់ព្រះពររបស់អ្នក។ សូមឱ្យខ្លួនអ្នក មានការអរព្រះគុណ ចំពោះអ្វីដែលល្អនៅក្នុងជីវិតរបស់អ្នក។ ជ្រើសរើសយកអំណរ។



Jackson, Wyoming

ដូចដែលយើងបាននិយាយម្តងហើយម្តងទៀត នៅក្នុងកម្រងសំណេរតែងសេចក្តីនេះ អ្នកមិនអាចដឹងពីអ្វីដែលព្រះនឹងធ្វើ ឬមិនធ្វើតាមសំណូមពររបស់អ្នកទេ។ ប៉ុន្តែ នោះមិនមែនជាចំណុចសំខាន់នៅត្រង់ចំណុចនេះទេ។ នៅពេលដែលអ្នករងបន្ទុកធ្ងន់ ដោយការថប់បារម្ភ លោកប៉ូលមានប្រសាសន៍ថា ចូរប្រមូលកង្វល់ទាំងអស់របស់អ្នក ហើយដាក់វាទៅក្នុងព្រះហស្តនៃព្រះវរបិតារបស់អ្នក ដែលគង់នៅស្ថានសួគ៌។ ចូលទៅជិតព្រះ ហើយរាប់ព្រះពររបស់អ្នក ព្រមទាំងពឹងផ្អែកលើទ្រង់ ដើម្បីជួយអ្នកតាមរបៀបដែលមានតែទ្រង់ប៉ុណ្ណោះ ទើបអាចធ្វើបាន។ នេះជាមាគ៌ាឆ្ពោះទៅរកសេចក្តីសុខសាន្តពិត និងស្ថិតស្ថេរ។

*ឯអ្នកណាដែលមានគំនិតជាប់តាមទ្រង់ នោះទ្រង់នឹងថែរក្សាអ្នកនោះ ឲ្យមានសេចក្តីសុខពេញខ្នាត ដោយព្រោះគេទុកចិត្តនឹងទ្រង់ ៤ ចូរទុកចិត្តដល់ព្រះយេហូវ៉ាជាដរាបចុះ ដ្បិតព្រះដ៏ជាព្រះយេហូវ៉ាទ្រង់ជាថ្មដាដ៏នៅអស់កល្បជានិច្ច។*

*អេសាយ ២៦:៣-៤*

*សប្តាហ៍ក្រោយ: តើការថប់បារម្ភរបស់អ្នក អាចបង្រៀនអ្នកពីអ្វី ដែលអ្នកត្រូវដឹងបំផុត*

---

**ជួយពួកយើងផ្សព្វផ្សាយពាក្យល្អ**! ដើម្បីឈានដល់មនុស្សកាន់តែច្រើន ដែលត្រូវការការលើកទឹកចិត្តខាងព្រះគម្ពីរ និងជាក់ស្តែងក្នុងពេលមានវិបត្តិសកល នៃជំងឺកូវីដ-១៩ យើងកំពុងបកប្រែអត្ថបទទាំងនេះជា ១០ ភាសាផ្សេងៗគ្នា ដែលប្រើប្រាស់នៅក្នុងផ្នែកផ្សេងៗនៃប្រទេសមីយ៉ាន់ម៉ា ឥណ្ឌា និងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ។ ប្រសិនបើអ្នកការប៉ះពាល់ចិត្ត ឬទទួលបានការលើកទឹកចិត្ត ដោយសារអត្ថបទមួយ ឬច្រើន សូមជួយផ្សព្វផ្សាយ ដោយចែករំលែកវា

ជាមួយអ្នកដទៃ និងតាមរយៈការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីឈានដល់មនុស្សកាន់តែច្រើនតាមរយៈ <u>**ការបរិច្ចាគទៅព័ន្ធកិច្ចសកល សម្រាប់សេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ នៅថ្ងៃនេះ។**</u>

---

ដើម្បីអានអត្ថបទមុនៗ ជាភាសាភូមា ភាសាឈីន ហិណ្ឌី សូមចូលទៅកាន់ “បណ្ណាល័យធនធាន” របស់យើង នៅលើគេហទំព័រ dhlglobal.org ។

---

**ខ្ញុំបានបង្កើតកម្រងសំណេរតែងនេះដើម្បីឆ្លើយតបទៅនឹងវិបត្តិជាសកល នៃជំងឺកូវីដ -២៩ តាមរយៈការបង្រៀនតាមព្រះគម្ពីរ គឺសមហេតុផលនៅក្នុងស្ថានភាពដែលមានការរងទុក្ខលំបាកជាច្រើន របស់មនុស្សជាតិ។ តែងសេចក្តីនីមួយៗ មានបន្ថែម ជូននូវការអនុវត្តជាក់ស្តែង ដែលត្រូវបានផ្តល់ជូន នៅក្នុងសៀវភៅមានចំណងជើងថា *អ្នកដឹកនាំដែលមានព្រះវិញ្ញាណទ្រង់នាំ៖ ប្រាំបួនគោលការណ៍នៃភាពជាអ្នកដឹកនាំ និងគោលការណ៍ខាងព្រលឹងវិញ្ញាណ* (HERNDON, VA: ALBAN INSTITUTE, ឆ្នាំ ២០០៥) ទំព័រ ១៨៤-៩០ ។**

---

Photo Credits:

- The first photo, with the huge crashing wave, is from the movie, *The Perfect Storm.*
- Photo of Tim praying with Burmese family ©Jill Geoffrion, { HYPERLINK "http://jillgeoffrion.com/" }
- Jackson, Wyoming photo, Timothy Charles Geoffrion, { HYPERLINK "http://www.thiswalkinglife.com/" }

Copyright © 2020 Timothy C. Geoffrion, Wayzata, Minnesota. All rights reserved to the author, but readers may freely download, print, forward, or distribute to others, providing that this copyright notice is included.

រក្សាសិទ្ធ © 2020 Timothy C. Geoffrion, ទីក្រុង Wayzata, រដ្ឋមីនេសូតា។ ក្សាសិទ្ធិគ្រប់បែបយ៉ាងជូនចំពោះអ្នកនិពន្ធ ប៉ុន្តែ ប្រិយមិត្តអាចទាញយក បោះពុម្ព បញ្ជូន ឬចែកចាយបន្តដល់អ្នកដទៃទៀតដោយសេរី គ្រាន់តែសូមរក្សាចំណារសម្គាល់នៃការរក្សាសិទ្ធិនេះជាមួយផង។

ប្រែសម្រួលភាសាដោយ: លី ប៊ុនថា